# កំណើនប្រកបដោយសមធម៌នៅឡូងប៊ិច

## គន្លងឆ្ពោះទៅវិបុលភាព

និវេសនជន ចំនួនប្រាំពីររូប ក្នុងចំណោម 10 រូប នៅឡូងប៊ិច គឺជាពលរដ្ឋមិនមែនស្បែកស ។ ប៉ុន្តែ វិសមភាពដោយសារ ជាតិសាសន៍ ភេទ និង ភូមិសាស្ត្រ នៅតែគម្រាមកំហែង ដល់កម្លាំងសេដ្ឋកិច្ចរបស់ទីក្រុង ។ ការឱបក្រសោប ភាពចម្រុះ ដែលចេះតែកើនឡើង ជាសម្បត្តិមួយ និង សមធម៌ ដែលកំពុងជឿនលឿន ទៅមុខជាការរួមបញ្ចូល ប្រកបដោយយុត្តិធម៌ និង ភាពត្រឹមត្រូវ ទៅក្នុងសង្គមជាតិ ដែលអ្នកទាំងអស់គ្នា អាចចូលរួម ទទួលបានវិបុលភាព និង សម្រេចបានសក្តានុពលពេញលេញ របស់ពួកគេ គឺជាគន្លងរបស់ទីក្រុង ឆ្ពោះទៅរកអនាគត ប្រកបដោយវិបុលភាព ។

### អ្នកជួលផ្ទះភាគច្រើននៅឡូងប៊ិច ពើបប្រទះនឹង បញ្ហាអសន្តិសុខ ផ្ទែកលំនៅដ្ឋាន ។

**ចំណែករបស់អ្នកជួលផ្ទះ ធ្វើការទូទាត់ ជាង 30% នៃចំណូល លើលំនៅដ្ឋាន តាមជាតិសាសន៍ ឆ្នាំ 2016**

| | |
|---|---|
| ទាំងអស់ | 56% |
| ស្បែកស | 51% |
| ស្បែកខ្មៅ | 61% |
| អាមេរិកខាងត្បូង | 59% |
| អាស៊ី ឬ ដីកោះប៉ាស៊ីហ្វិក | 50% |
| ចម្រុះ/ផ្សេងៗទៀត | 47% |

អ្នកជួលផ្ទះ ជាជនស្បែកខ្មៅ និងអាមេរិកខាងត្បូង នៅឡូងប៊ិច មានទំនោរច្រើន ក្នុងការជាប់បន្ទុកពីថ្លៃជួលផ្ទះ ដោយមានប្រមាណ ប្រាំមួយ ក្នុង 10 នៃការទូទាត់ ជាង 30% នៃចំណូល របស់ពួកគេ លើលំនៅដ្ឋាន ។

### ឡូងប៊ិច ត្រូវតែកាត់បន្ថយ ភាពក្រីក្រ របស់ប្រជាពលករ ដែលមានចំណូលក្រោមបន្ទាត់ក្រីក្រ ដើម្បីឱ្យពួកគេ មានការរីកចម្រើន ។

**ចំណែក នៃពលករ ជាមនុស្សធំពេញវ័យ អាយុ 25–64 ឆ្នាំ ដែលធ្វើការងារពេញម៉ោង និងរស់នៅ ក្រោម 200% នៃកម្រិតក្រីក្រ តាមជាតិសាសន៍ និងភេទ ឆ្នាំ 2016**

| | | |
|---|---|---|
| ទាំងអស់ | ស្រី | 10% |
| | ប្រុស | 15% |
| ស្បែកស | ស្រី | 5% |
| | ប្រុស | 4% |
| ស្បែកខ្មៅ | ស្រី | 11% |
| | ប្រុស | 8% |
| អាមេរិកខាងត្បូង | ស្រី | 16% |
| | ប្រុស | 26% |
| អាស៊ី ឬ ដីកោះប៉ាស៊ីហ្វិក | ស្រី | 9% |
| | ប្រុស | 11% |
| ចមេះ/ផេរងៗទៀត | ស្រី | 8% |
| | ប្រុស | 10% |

ជាង មួយភាគបួននៃពលករ ជាប្រុសអាមេរិកខាងត្បូង ដែលធ្វើការងារពេញម៉ោង មិនរកប្រាក់បានគ្រប់គ្រាន់ ដើម្បីទ្រទ្រង់គ្រួសារ របស់ពួកគេ នោះទេ ។

### សេដ្ឋកិច្ចរបស់ឡូងប៊ិច អាចខ្លាំងក្លាជាងមុនជាមួយនឹងសមធម៌។

**កំណើនប៉ាន់ស្មាន នៃផលិតផលក្នុងស្រុកសរុប របស់ទីក្រុងឡូសអ៊ែនជឺឡេស (គិតជាពាន់លាន) ប្រសិនបើគម្លាតចំណូល តាមជាតិសាសន៍ ត្រូវបានរួមភ្ជិត ។**

| 2010 | 2015 | 2040 |
|---|---|---|
| 407B | 502B | ? |

**សមធម៌ គឺជាគន្លង ដែលត្រូវដើរទៅមុខទៀត ។**
កិច្ចខិតខំប្រឹងប្រែង ថ្មីៗ នេះ បង្ហាញថា អ្នកដឹកនាំ នៅមូលដ្ឋាន មានការប្តេជ្ញាចិត្ត ចំពោះសមធម៌ ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ រួមមាន ការបង្កើតការិយាល័យសមធម៌ របស់ទីក្រុង និង គំនិតផ្តួចផ្តើមអ្នកគ្រប់គ្នាស្ថិតក្នុងបរិយាប័ន្នសេដ្ឋកិច្ច ។
យុទ្ធសាស្ត្របន្ថែម ៖

**1) រំលាយរបាំងជាតិសាសន៍ និង ធានាឱ្យមាន ការអភិវឌ្ឍ ប្រកបដោយសមធម៌ ។** លើកកម្ពស់សមធម៌ ក្នុងចំណោមនិវេសនជន ដោយ ៖ (a) កំណត់អាទិភាព លើសេចក្តីត្រូវការនានា របស់សហគមន៍ចំណូលទាប ដែលមិនមានស្បែកស និង បង្កើនភាពចម្រុះ នៃមន្ត្រីសាលាក្រុងដែលបានតែងតាំង (b) ពង្រីកកិច្ចគាំពារអ្នកជួលផ្ទះ (ដូចជា ការបណ្តេញចេញ ដោយបុព្វហេតុណាមួយ ការរក្សាស្ថេរភាពថ្លៃឈ្នួល កិច្ចគាំពារទប់ទល់នឹងការផ្លាស់ទីលំនៅ) និង (c) ធានាឱ្យសហគមន៍មានសុខភាពល្អ ដោយការដាក់កម្រិត លើការពង្រីកអន្តរដ្ឋ និងដោយរួមបញ្ចូលប្រកដឹកជញ្ជូនដែលគ្មានផ្សែងពុល ។

**2) បង្កើតការងារល្អៗ ដោយ ៖** (a) គាំទ្រអាជីវកម្ម ដែលកាន់កាប់ ដោយអ្នកមិនមានស្បែកស និងស្ត្រី តាមរយៈ ការចុះកិច្ចសន្យា និងការគាំទ្រអាជីវកម្ម ប្រកបដោយសមធម៌ (b) ពង្រឹង កិច្ចព្រមព្រៀងការងារគម្រោង របស់ក្រុង ដើម្បីពង្រីកការងារ សម្រាប់ពលករ ដែលប្រឈមនឹងឧបសគ្គ ក្នុងការទទួលបានការងារ និង (c) ធានាឱ្យមាន ប្រាក់ឈ្នួលអប្បបរមា សម្រាប់និយោជិតទាំងអស់ ។

**3) រៀបចំត្រៀមលក្ខណៈពលករ សម្រាប់ការងារថ្ងៃអនាគតដោយ ៖** (a) បង្កើនការគាំទ្រ សម្រាប់ ការអប់រំកុមារ នៅបឋមវ័យ (b) រៀបចំត្រៀមលក្ខណៈយុវជន និងមនុស្សធំពេញវ័យ ដែលគ្មានការងារធ្វើ សម្រាប់ការងាររដ្ឋាភិបាល ដោយសារចំនួនជាច្រើន នៃមន្ត្រីទាំងនោះ នឹងចូលនិវត្តន៍ និង (c) ធានាថាសិស្សនិស្សិតទាំងអស់ មានគន្លង តម្រង់ទៅរក ការអប់រំ កម្រិតឧត្តមសិក្សា និង/ឬ សាលាពាណិជ្ជសាស្ត្រ ។

សូមអាន កម្រងឯកសារសមធម៌ ៖ www.nationalequityatlas.org/reports/equity-profiles
សម្រាប់ព័ត៌មានបន្ថែមទៀត សូមទំនាក់ទំនង ចាមីឡា ហ៊ែនឌឺសុន (Jamila Henderson) ៖
jamila@policylink.org
©2019 ដំណរគោលនយោបាយ (PolicyLink) ។ រក្សាសិទ្ធិគ្រប់យ៉ាង ។

PolicyLink USC Dornsife Program for Environmental and Regional Equity citi